## ព្រះរាជក្រឹត្យ

នស/រកត/១២០៩/១១៧១

## ស្តីពី

### ការតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា និងការកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា

**យើង**

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពិសិដ្ឋប្រាជ្ញាញាណមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស ឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានយល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៩/៩៤៣ ចុះថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ២០០៩ ស្តីពីការកែសម្រួល និងការធ្វើនិយតភាព ការបង្កើតគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា
- បានទ្រង់យល់សេចក្តីក្រាបថ្វាយបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានតែងតាំងសមាសភាពរបស់គណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដូចតទៅ ៖

| | | |
|---|---|---|
| - ឯកឧត្តម លឹម គានហោ | រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម | ប្រធាន |
| - ឯកឧត្តម ម៉ុក ម៉ារ៉េត | ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន | អនុប្រធាន |
| - ឯកឧត្តម ត្រាំ អ៊ីវតឹក | រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន | អនុប្រធាន |
| - ឯកឧត្តម ស៊ិន នីនី | | អនុប្រធានអចិន្ត្រៃយ៍ មានឋានៈស្មើរដ្ឋមន្ត្រី |
| - ឯកឧត្តម ចក់ ឡេង | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - ឯកឧត្តម អ៊ុច បូររិទ្ធ | រដ្ឋលេខាធិការក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ | សមាជិក |
| - ឯកឧត្តម សក់ សេដ្ឋា | រដ្ឋលេខាធិការក្រសួងមហាផ្ទៃ | សមាជិក |
| - ឯកឧត្តម ម៉ុន ហ៊ាន | រដ្ឋលេខាធិការក្រសួងធនធានទឹក និងឧតុនិយម | សមាជិក |
| - ឯកឧត្តម វ៉ោន គុលបុត្រ | រដ្ឋលេខាធិការក្រសួងបរិស្ថាន | សមាជិក |
| - ឯកឧត្តម ជៅ ទ្រី | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| - ឯកឧត្តម ម៉ុម ស៊ីបុន | រដ្ឋលេខាធិការក្រសួងសាធារណការ និងដឹកជញ្ជូន | សមាជិក |

ROYAUME DU CAMBODGE

- ឯកឧត្តម សាត សាមី — រដ្ឋលេខាធិការក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល — សមាជិក
- ឯកឧត្តម ហ៊ូ តាំងអេង — រដ្ឋលេខាធិការក្រសួងផែនការ — សមាជិក
- ឯកឧត្តម សួស គង់ — រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ — សមាជិក
- ឯកឧត្តម ឈឹម កៃលាង — រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ — សមាជិក
- ឯកឧត្តម គោស៊ុំ សារឿត — រដ្ឋលេខាធិការក្រសួងទេសចរណ៍ — សមាជិក
- ឯកឧត្តម អ៊ុំ ម៉ុនឈួង — រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- លោកជំទាវ ច័ន្ទ សូរីយ៍ — រដ្ឋលេខាធិការក្រសួងកិច្ចការនារី — សមាជិក
- ឯកឧត្តម ពៅ សាមី — អគ្គលេខាធិការគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ — សមាជិក
- ឯកឧត្តម សុខ ចិន្តា — រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍកម្ពុជា — សមាជិក
- ឯកឧត្តម សាយ សំអាល់ — អនុប្រធានអចិន្ត្រៃយ៍ និងជាអគ្គលេខាធិការអាជ្ញាធរទន្លេសាប — សមាជិក

មាត្រា ២: ត្រូវបានកែសម្រួលឋានៈរបស់ថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា ដូចតទៅ :

១- ឯកឧត្តម ពេជ ឌុន អគ្គលេខាធិការគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ **រដ្ឋលេខាធិការ**

២- ឯកឧត្តម តែ ណាវុធ អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៣- ឯកឧត្តម គល់ វឌ្ឍនា អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៤- ឯកឧត្តម សូ សុភ័ន្ធ អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជា មានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

៥- ឯកឧត្តម វ៉ាត់ បុត្តកុសល អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ **អនុរដ្ឋលេខាធិការ**

៦- ឯកឧត្តម អានពេជ្រហត្ថដា អគ្គលេខាធិការរងគណៈកម្មាធិការជាតិទន្លេមេគង្គកម្ពុជាមានឋានៈស្មើ**អនុរដ្ឋលេខាធិការ**

មាត្រា ៣ : រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ : ព្រះរាជក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

*៣៧.០៩១៤.១២០៧*

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

*ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៩*

លេខ: ១១០៤ ច.ល

**ដើម្បីចម្លងចែក**

រាជធានីភ្នំពេញ, ថ្ងៃទី២២ ខែ ធ្នូ ឆ្នាំ២០០៩

**អគ្គលេខាធិការរងរាជរដ្ឋាភិបាល**

**ឃុន ជិនកេន**